ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ..............................

## កំណត់ហេតុ
## ប្រជុំស្តីពី ការពិគ្រោះយោបល់ អំពើពេស្យាចារ និងអំពើពេស្យាចារកុមារ

ឆ្នាំពីរពាន់ដប់ប្រាំពីរ ខែមករា ថ្ងៃទីដប់បី វេលាម៉ោងប្រាំបួន ព្រឹក នៅសាលប្រជុំអគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ **និងជាអនុប្រធានអចិន្ត្រៃយ៍** គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធាននាយកដ្ឋាន ចំណុះគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១.ឯកឧត្តម ឧ.ឯ | **ថោង សំអាត** | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ២.ឯកឧត្តម ឧ.ឯ | **យឹម វិរៈ** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៣.ឯកឧត្តម ឧ.ឯ | ស៊ុន រ៉ូ | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៤.ឯកឧត្តម ឧ.ឯ | ខៀវ ចាន់រ៉ា | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៥.ឯកឧត្តម ឧ.ឯ | ប៉ុល ភិជេយ្យ | ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ |
| ៦.លោកជំទាវ ឧ.ឯ | ប៉ុណ្ណ សំខាន់ | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៧.លោកជំទាវ | រ៉ែន សិរីលក្ខិណា | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៨.ឯកឧត្តម ឧ.ទោ | យ៉ែម ច័ន្ទណារុំ | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៩.ឯកឧត្តម ឧ.ទោ | អ៊ូ ម៉ានីរ៉ា | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ១០.លោក ឧ.ត្រី | សុខ ស្មើ | ប្រធាននាយកដ្ឋាន គ.ជ.ប.ជ |
| ១១.លោក ឧ.ត្រី | កែប សារឿន | ប្រធាននាយកដ្ឋាន គ.ជ.ប.ជ |
| ១២.លោក ឧ.ត្រី | គង់ ពុទ្ធី | ប្រធានលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ១២.លោក វ.ទោ | ឌិក សត្យា | នាយរងការិយាល័យផ្សព្វផ្សាយ អប់រំ |
| ១៣.លោក វ.ត្រី | ដៀប នួច | នាយរងការិយាល័យផ្សព្វផ្សាយ អប់រំ |
| ១៤.លោក អនុ.ឯក | សៅ ស៊ីនួន | នាយរងការិយាល័យផ្សព្វផ្សាយ អប់រំ |

ជាកិច្ចចាប់ផ្តើម **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានមានប្រសាសន៍ស្វាគមន៍យ៉ាងកក់ក្តៅចំពោះ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដែលមាន

វត្តមាននៅក្នុងអង្គប្រជុំពិភាក្សាពិគ្រោះយោបល់ ស្តីពីអំពើពេស្យាចារ និងអំពើពេស្យាចារកុមារ នាពេលនេះ។ បន្ទាប់មក **លោកជំទាវ** បានមានប្រសាសន៍ពាក់ព័ន្ធនឹងស្ត្រីពេស្យាចារម្នាក់ដែលបានរត់គេចពីការចាប់ខ្លួនរបស់អាជ្ញាធរមានសមត្ថកិច្ច ហើយបណ្តាលឲ្យស្ត្រីនោះលោតធ្លាក់ទឹកទន្លេសាបនាពេលកន្លងមកនេះ។ ករណីនេះតាមការពិនិត្យជាក់ស្តែងគឺ មកពីការធ្វេសប្រហែសរបស់អាជ្ញាធរ ដោយពុំមានវិធានការគ្រប់គ្រងច្បាស់លាស់លើមូលដ្ឋានរបស់ខ្លួនធ្វើឲ្យកើតមានអំពើពេស្យាចារជាបន្តបន្ទាប់យ៉ាងដូចនេះ។

បន្ទាប់មក លោកឧត្តមសេនីយ៍ត្រី **សុខ រស្មី** ប្រធាននាយកដ្ឋាន ក្រុមការងារទំនាក់ទំនងកិច្ចការអន្តរជាតិ បានឡើងធ្វើបទបង្ហាញ ស្តីពីទិដ្ឋភាពទូទៅ នៃអំពើពេស្យាចារ នៅលើពិភពលោក ក្នុងតំបន់ និងនៅប្រទេសកម្ពុជាយើង អំពីចំនួនតួលេខតាមការស្រាវជ្រាវរបស់អង្គការសហប្រជាជាតិ(UNICEF) និងអង្គការមួយចំនួនទៀត ដែលមានខ្លឹមសារដូចខាងក្រោម៖

១.និយមន័យ នៃអំពើពេស្យាចារ

២.ពេស្យាចារ នៅកម្ពុជា

៣.ស្ថានភាព នៃច្បាប់ការងារផ្លូវភេទនៅតាមប្រទេសលើពិភពលោកឆ្នាំ២០១៦

៤.ស្ថិតិចំនួនពេស្យាចារនៅតាមប្រទេសក្នុងពិភពលោក

៥.ការចំណាយថវិការទៅលើពេស្យាចារ នៅទូទាំងពិភពលោក

៦.ការសន្និដ្ឋានហេតុផលទាំង១០ សម្រាប់ការមិនអនុញ្ញាតិច្បាប់ពេស្យាចារ

ពេស្យាចារ នៅកម្ពុជាយើងគឺ កើតមានតាំងពីយូរណាស់មកហើយ ការធ្វើរបពេស្យាចារនេះជាអំពើល្មើសច្បាប់ និងមានការផ្លាស់ប្តូរភេទបានកើតមាននៅកម្ពុជានៅក្នុងសតវត្សនេះ។ នៅក្នុងឆ្នាំ១៩៧៩ ដល់១៩៩៣ ការធ្វើជំនួញផ្លូវភេទក៏ចាប់ផ្តើមកើតមានឡើង រហូតដល់ឆ្នាំ១៩៩២,១៩៩៣ មានវត្តមានកងកម្លាំងរក្សាសន្តិភាព អង្គការសហប្រជាជាតិ (UN) និងបណ្តាអង្គការមិនមែនរដ្ឋាភិបាលជាច្រើនទៀត ចូលមកកម្ពុជាយើងក៏បានបង្កើតឡើងទីផ្សាររបំរើសេវាផ្លូវភេទ ការរំលោភបំពាន និងការធ្វើឲ្យខូចកិត្តិយសស្ត្រីកម្ពុជាផងដែរ។ ក្រោយពីកងកម្លាំងរក្សាសន្តិភាព ដកចេញពីកម្ពុជានៅចុងឆ្នាំ១៩៩៣ សេវាបម្រើផ្លូវភេទ(អំពើពេស្យាចារ) មានការថយចុះទៅវិញបន្តិច។ ប៉ុន្តែមកដល់ឆ្នាំ១៩៩៤ ចំនួនតួលេខពេស្យាចារមានកើនឡើងសារជាថ្មី ពេស្យាចារទាំងនោះច្រើនមានអាយុចាប់ពីចន្លោះ ១៥ឆ្នាំ ទៅ១៨ឆ្នាំ ដូចជានៅតាមតំបន់ទួលគោក និងស្វាយប៉ាក នៃរាជធានីភ្នំពេញ។ នៅឆ្នាំ១៩៩៥ ស្ត្រីពេស្យាចារ ជាជនបរទេស និងប្រទេសជិតខាងបានមកបង្ហាញខ្លួននៅប្រទេសកម្ពុជាយើង។

ឆ្នាំ២០០៨ ច្បាប់ការបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទត្រូវបានអនុម័តឡើង ធ្វើឲ្យអំពើពេស្យាចារមានការថយចុះ ផ្ទះបនសម្រាប់បម្រើសេវាផ្លូវភេទនៅតាមតំបន់ដែលធ្លាប់មាន ត្រូវបានបង្ក្រាបដោយមានយុទ្ធនាការដូចភ្លៀងលើមរបស់អគ្គស្នងការនគរបាលជាតិ។

នៅកម្ពុជាយើងចំនួនតួលេខពេស្យាចារ និងប្រាក់ចំណូលក្នុង១ឆ្នាំ កើនដល់ ៥១១ដុល្លារអាមេរិក ដោយការចាយវាយរបស់បរទេស និងអ្នករកសេវាផ្លូវភេទក្នុងប្រទេស។ ដោយមានហេតុផល ៣ចំណុច ដែលបុរសត្រូវការចំណាយលើសេវាផ្លូវភេទគឺ ការបំពេញចំណង់ផ្លូវភេទភ្លាមៗ, បទពិសោធន៍ជារូបវន្តជាក់លាក់ នៃជាតិសាសន៍ ឬការមានចំណង់ផ្លូវភេទ និងមិនបញ្ជាក់ពីចំនួនចំៗ នៅក្នុងទំនាក់ទំនងថ្មីរបស់ពួកគេ។ ពាក់ព័ន្ធលើហេតុផលទាំង ៣

ចំណុចខាងលើនេះគេបានរកឃើញមានស្រ្តីរងគ្រោះចំនួន ២.៥ លាននាក់ត្រូវបានគេជួញដូរថ្មីៗនេះ គឺចំនួន ២/៣ ត្រូវបានគេយកមកពីអឺរ៉ុប ខាងកើត។ ក្នុងឆ្នាំ២០១៦ កម្ពុជាមានចំនួនតួលេខ នៃស្រ្តីពេស្យាចារមានដល់ ៧០,០០០នាក់ ពិនិត្យរួមតួលេខពេស្យាចារនៅលើពិភពលោក គឺមានចំនួន ៤០លាននាក់ស្មើនឹងចំនួនប្រជាជនអូស្ត្រាលី ២១លាននាក់ និងកាណាដា ចំនួន ៣៣លាននាក់។

តាមការសិក្សាបានបង្ហាញឲ្យឃើញថា៖ មានបុរសម្នាក់ក្នុងចំណោម ១០នាក់នៅលើពិភពលោក បានទិញពេស្យាចារកុមារ និងបុរសចំនួន១/៥, លើពិភពលោកត្រូវបានលួចមានស្រីខាងក្រៅផ្ទះជាមួយស្រីពេស្យាចារ។ **សម្រាប់ការចំណាយរបស់បុរសទៅលើសេវាផ្លូវភេទ(ពេស្យាចារ) ទូទាំងពិភពលោក គឺមានទឹកប្រាក់សរុបចំនួន ១៨៦ កោដិ ដុល្លារ សហរដ្ឋអាមេរិក ក្នុងនោះមានបណ្ដាប្រទេសមួយចំនួនដូចខាងក្រោម៖**

| | | |
|---|---|---|
| ១.ប្រទេសចិន | ចំនួន ៧៣ | កោដិ |
| ២.ប្រទេសជប៉ុន | ចំនួន ២៦,៥ | កោដិ |
| ៣.ប្រទេសកូរ៉េខាងត្បូង | ចំនួន ១២ | កោដិ |
| ៤.ប្រទេសឥណ្ឌា | ចំនួន ៨,៤ | កោដិ |
| ៥.ប្រទេសថៃ | ចំនួន ៦,៤ | កោដិ |
| ៦.ប្រទេសហ្វីលីពីន | ចំនួន ៦ | កោដិ |
| ៧.ប្រទេសអាឡឺម៉ង់ | ចំនួន ១៨ | កោដិ |
| ៨.សហរដ្ឋអាមេរិក | ចំនួន ១៤,៦ | កោដិ |
| ៩.ប្រទេសតួគី | ចំនួន ៤ | កោដិ |
| ១០.ប្រទេសអេស្ប៉ាញ | ចំនួន ២៦ | កោដិ |

**ហេតុផលទាំង១០ សម្រាប់ការមិនអនុញ្ញាតច្បាប់ ពេស្យាចារ**

១.ការអនុញ្ញាតដោយច្បាប់ / ការលើកលែងទោសពីបទល្មើសព្រហ្មទណ្ឌ នៃអំពើពេស្យាចារជាអំណោយផលសម្រាប់សញ្ជាវិក សញ្ជាវិកា ឈ្មួញជួញដូរ និងឧស្សាហកម្មផ្លូវភេទ។

២.ការអនុញ្ញាតដោយច្បាប់ / ការលើកលែងពីបទព្រហ្មទណ្ឌ នៃអំពើពេស្យាចារ និងឧស្សាហកម្មផ្លូវភេទ គឺជាការលើកទឹកចិត្តការជួញដូរផ្លូវភេទ។

៣.ការអនុញ្ញាតដោយច្បាប់ / ការលើកលែងពីបទព្រហ្មទណ្ឌ នៃអំពើពេស្យាចារ មិនអាចត្រួតពិនិត្យឧស្សាហកម្មផ្លូវភេទ និងធ្វើឲ្យកាន់តែរីករាលដាល។

៤.ការអនុញ្ញាតដោយច្បាប់ / ការលើកលែងពីបទព្រហ្មទណ្ឌ នៃអំពើពេស្យាចារ បង្កើនការលួចលាក់ផ្ទុយនឹងច្បាប់ និងអំពើពេស្យាចារនៅតាមផ្លូវ។

៥.អំពើពេស្យាចារស្របច្បាប់ និងការលើកលែងឧស្សាហកម្មផ្លូវភេទពីបទល្មើសព្រហ្មទណ្ឌ ធ្វើឲ្យពេស្យាចារកុមារកើនឡើង។

៦.ការអនុញ្ញាតដោយច្បាប់ / ការលើកលែងឧស្សាហកម្មផ្លូវភេទពីបទល្មើសព្រហ្មទណ្ឌ គឺមិនមែនជាបំណងរបស់ស្រ្តីពេស្យាចារទេ។

៧.ការអនុញ្ញាតដោយច្បាប់ / ការលើកលែងឧស្សាហកម្មផ្លូវភេទពីបទល្មើសព្រហ្មទណ្ឌ គឺធ្វើឲ្យតម្រូវការពេស្យាចារកើនឡើង និងលើកទឹកចិត្តឲ្យបុរសទិញស្ត្រីកាន់តែទូលំទូលាយ និងអនុញ្ញាតឲ្យអំពើនេះគ្របដណ្តប់ និងទទួលយកបានពីសង្គម។

៨.ការអនុញ្ញាតដោយច្បាប់ / ការលើកលែងឧស្សាហកម្មផ្លូវភេទពីបទល្មើសព្រហ្មទណ្ឌ គឺវាមិនបានលើកកម្ពស់សុខភាពរបស់ស្ត្រីទេ។

៩.ការអនុញ្ញាតដោយច្បាប់ / ការលើកលែងឧស្សាហកម្មផ្លូវភេទពីបទល្មើសព្រហ្មទណ្ឌ គឺវាមិនមែនជាជម្រើសរបស់ស្ត្រីទេ។

១០.ស្ត្រីក្នុងប្រព័ន្ធ នៃអំពើពេស្យាចារមិនចង់ឲ្យឧស្សាហកម្មផ្លូវភេទស្របច្បាប់ ឬការលើកលែងពីបទល្មើសព្រហ្មទណ្ឌទេ។

ចំពោះប្រទេស ស៊ុយអែត គេបានដាក់អំពើពេស្យាចារជាអំពើខុសច្បាប់ មិនឲ្យកើតមានតែម្តង។

ប្រសាសន៍ **ឯកឧត្តម ឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរ និង **ការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ** បានលើកឡើងអំពីការវិវត្តន៍នៃអំពើពេស្យាចារ ក្រោយពីប្រទេសកម្ពុជាយើងបានរំដោះរួចផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត(របបខ្មែរក្រហម)។ នៅឆ្នាំ១៩៨០ អំពើពេស្យាចារបានកើតមានជាលក្ខណៈទ្រង់ទ្រាយតូចៗ ហើយគ្មានការកេងប្រវ័ញ្ចទៅលើស្ត្រីរកស៊ីផ្លូវភេទនោះទេ។ ពួកគេ (ស្រីពេស្យាចារ) ប្រមូលផ្តុំគ្នាជាក្រុមតូចៗ ពី៤ ទៅ៥នាក់ បើកជាកន្លែងម៉ាស្សា កោសជប់ និងរួមភេទទៅតាមការស្ម័គ្រចិត្ត ដូចជានៅក្នុងរាជធានីភ្នំពេញ កើតមាននៅតំបន់ត្រឡោកបែក ទួលគោក សុខាល័យ បឹងកំប្លោក ចាក់អង្រែជាដើម។ នៅឆ្នាំ១៩៨៩ ដល់ឆ្នាំ១៩៩០ អំពើពេស្យាចារកើតមានតាមហាងលក់កាហ្វេរបស់ជនជាតិវៀតណាម ជាប់ព្រំដែន និងតំបន់ស្វាយប៉ាក។ ឆ្នាំ១៩៩០ ដល់២០០០ មានជនជាតិវៀតណាមជ្រៀតចូលមករកស៊ីនៅក្នុងប្រទេសកម្ពុជាយើង អំពើពេស្យាចារបានកើតឡើងយ៉ាងខ្លាំង ដោយសារមានវត្តមានរបស់ UN(អ៊ុនតាក់)។ ពួកគេបានបង្កើតមានជាមេបន ដោយជ្រកក្រោមស្លាកអាជីវកម្ម ហាងលក់កាហ្វេ លក់គ្រឿងក្លែម និងជាផ្ទះបនស្រីពេស្យាចារតែម្តង។ មេបនបានប្រើប្រាស់បណ្តាញរបស់ខ្លួនឲ្យធ្វើការអូសទាញ ស្រីក្មេងៗ និងជំទង់ៗ ពីតាមទីជនបទ និងទីប្រជុំជន និងនាំមកពីប្រទេសវៀតណាមឲ្យមកធ្វើជាស្រីបម្រើសេវាផ្លូវភេទនៅផ្ទះបនរបស់ខ្លួន ហាងម៉ាស្សា ក្លឹមខារ៉ាអូខេ ជាច្រើនទៀតបានផ្តល់សេវាបម្រើផ្លូវភេទនៅទីនោះដែរ។

ទន្ទឹមនឹងនោះ ក៏កើតចេញនូវបាតុភាពជួញដូរព្រហ្មចារីយ៍លើក្មេងស្រីពីអាយុ ១៥ឆ្នាំ ដល់១៧ឆ្នាំ ក្មេងស្រីទាំងនោះភាគច្រើនជាជនជាតិវៀតណាម។ ក្រោយពីជួញដូរព្រហ្មចារីយ៍រួចហើយក្មេងស្រីទាំងនោះត្រូវបានគេយកមកឲ្យបម្រើសេវាផ្លូវភេទក្នុងផ្ទះបន និងទីកន្លែងផ្សេងៗទៀតជាបន្ត។

នៅឆ្នាំ២០០៣ អំពើពេស្យាចារត្រូវបានថមថយទៅវិញ ដោយមានការបង្ក្រាបរបស់សមត្ថកិច្ចផ្ទះបនត្រូវបានបិទជាស្ថាពរ។ លុះដល់ឆ្នាំ២០០៨ ច្បាប់ការបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទត្រូវបានអនុម័ត ហើយអំពើពេស្យាចារត្រូវបានផ្លាស់ប្តូរពីចំហរទៅលាក់បាំង ដោយបើកហាងកាត់សក់ ម៉ាស្សា ខារ៉ាអូខេ ហាងកាហ្វេ។ ហើយមកដល់បច្ចុប្បន្ននេះអំពើពេស្យចារកំពុងកើតឡើងវិញជាបន្តបន្ទាប់នៅក្នុងរាជធានីភ្នំពេញ។

**ឯកឧត្តម ឧត្តមសេនីយ៍ឯក ប៉ុល តិចេយ្យ** បានសុំឲ្យលោក ឧត្តមសេនីយ៍ត្រី សុខ ស្មើ និងលោក ឧត្តមសេនីយ៍ត្រី កែប សារឿន សហការជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កែសម្រួលលើរបាយការណ៍ពាក់ព័ន្ធអំពើពេស្យាចារឲ្យបានត្រឹមត្រូវ។

ប្រសាសន៍ **ឯកឧត្តម ឧត្តមសេនីយ៍ឯក ថោង សំអាត** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានឯកភាពលើការលើកហេតុផល ទាំង១០ សម្រាប់ពេស្យាចារមិនស្របច្បាប់ ដែល លោក **ឧត្តមសេនីយ៍ត្រី សុខស្មើ** បានលើកបង្ហាញតាមការបញ្ចាំង ស្លាយ(Slide) នឹងបានចាត់បញ្ជូន **ឯកឧត្តម ស៊ិន រ៉ូ** និង **លោកឧត្តមសេនីយ៍ត្រី សុខ ស្មើ** សហការជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ក្នុងការអភិវឌ្ឍន៍របាយការណ៍ពាក់ព័ន្ធអំពើពេស្យាចារនេះ។

ប្រសាសន៍ **ឯកឧត្តម ឧត្តមសេនីយ៍ឯក យឹម ទិរៈ** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជះពាក់ព័ន្ធនូវអំពើពេស្យាចារនេះ គឺច្បាប់យើងមានស្រាប់ស្ថិតក្នុងជំពូកទី៤ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ។ អំពើពេស្យាចារសព្វថ្ងៃនេះច្រើនកើតមាននៅក្នុងក្លឹបកំសាន្ត ខារ៉ាអូខេ ហាងម៉ាស្សាកាត់សក់ ពុំមានជាលក្ខណៈបើចំហរដូចមុនទេ។

ចំពោះស្រីពេស្យាចារចាប់ពីអាយុ១៨ឆ្នាំ ឡើងការរួមភេទជាមួយបុរសគឺ គេពុំមានទោសទេសម្រាប់បុរស។ ដោយឡែកសម្រាប់ពេស្យាចារកុមារវិញ អាយុក្រោម១៨ឆ្នាំគឺ បុរសត្រូវមានទោសព្រោះច្បាប់បានកំណត់រួចស្រេចហើយ។

ប្រសាសន៍ **លោកជំទាវ រ៉ែន សិរីលក្ខិណា** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អំពើពេស្យាចារនៅកម្ពុជាយើងគឺ កើតមានតាំងពីមុនមកហើយ រហូតមកដល់ជំនាន់នេះអំពើពេស្យាចារក៏នៅកើតមានដដែល តែវាពុំមានលក្ខណៈទូលំទូលាយដូចកាលអំឡុងពេល UN និងសង្គមស៊ីវិលចូលមកនោះទេ គឺសង្កេតឃើញមាននៅតាមតំបន់មួយចំនួន។ អំពើពេស្យាចារកើតមានកន្លងមកធ្លាប់មានបាតុភាពតវ៉ាផងដែរ ដោយស្ត្រីពេស្យាចារទាំងនោះសុំឲ្យរដ្ឋាភិបាលបង្កើតនូវសេវាថែទាំសុខភាពដល់ពួកគេផងដែរ ពេលនោះ ដឹកនាំដោយ លោកស្រី មូ សុខហួរ ហើយយើងបានឲ្យស្ត្រីពេស្យាចារទាំងនោះនៅក្នុងតំបន់មយយចំនួនដូចជា ឈូកស ទួលគោក ស្វាយប៉ាក ជាដើម។

ប្រសាសន៍ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានលើកយកបញ្ហាពេស្យាចារដាក់ឲ្យទៅជាស្របច្បាប់នោះគឺ វាធ្វើឲ្យប៉ះពាល់ដល់សង្គមជាតិយើងខ្លាំងណាស់។ ពិសេសវប្បធ៌មប្រពៃណី ទំនៀមទំលាប់ស្ត្រីខ្មែរហើយវាផ្ទុយ នឹងច្បាប់ដែលយើងបានសម្រេច និងអនុម័តតាំងពីឆ្នាំ២០០៨ មកម្លេះ។

នៅប្រទេសឥណ្ឌា នេប៉ាល់ គេបង្កើតឲ្យអំពើពេស្យាចារនេះស្របច្បាប់។ ហើយស្ត្រីពេស្យាចារនោះ គឺពួកគេបានប្រមូលផ្តុំដើម្បីស្វែងរកសេវាផ្លូវភេទ រហូតដល់មានសមត្ថកិច្ចនគរបាលយាមការពារទីកន្លែងដែលពួកគេប្រមូលផ្តុំគ្នាថែមទៀតផង។ បើពិនិត្យលើផលទទួលបានពីសេវាផ្លូវភេទនេះ អ្នកទទួលបានផលចំណេញច្រើនគឺ ថៅកែ ឬមេបន ទៅវិញទេខុសពីស្ត្រីរកស៊ីផ្លូវភេទ។ ឥលូវនេះបញ្ហា ជំងឺអេដស៍មានការថយចុះច្រើន តែអំពើពេស្យាចារចាប់កើតមានជាបន្តបន្ទាប់ទៀតហើយ។ តើយើងត្រូវធ្វើការគ្រប់គ្រងដោយរបៀបណា? កាលសង្គមមុន ស្រីពេស្យាចារ គេបាន

ចេញកាតឲ្យប្រើប្រាស់ដើម្បីកុំឲ្យច្រឡំជាមួយស្ត្រីដទៃទៀត។ សរុបសេចក្តីមកគឺ កុំឲ្យកើតមានតែម្តងប្រសើរជាង។

ចុងបញ្ចប់ **លោកជំទាវ ជូ ប៊ុនអេង** បានឯកភាពទទួលយកការលើកឡើងនូវបទបង្ហាញរបស់ លោក **ឧត្តមសេនីយ៍ត្រី សុខ រស្មី** ប្រធាននាយកដ្ឋានទំនាក់ទំនងកិច្ចការអន្តរជាតិ ហើយសុំឲ្យលោក **ឧត្តមសេនីយ៍ត្រី សុខ រស្មី** ដាក់ឯកសារដែលបានយកមកធ្វើបទបង្ហាញនេះរបស់នរណា? ដាក់ឈ្មោះផង? សម្រាប់ថ្ងៃខាងមុខ លោកជំទាវ នឹងជួបប្រជុំជាមួយអន្តរក្រសួង ស្ថាប័នតុលាការ អង្គការ និងសារព័ត៌មានក្នុងស្រុក អន្តរជាតិជាបន្តបន្ទាប់ទៀត។

អង្គប្រជុំពិភាក្សាបានបញ្ចប់នៅវេលាម៉ោង ដប់មួយ និង ហាសិបនាទី ថ្ងៃខែឆ្នាំដដែល។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ មករា ឆ្នាំ២០១៧

**អ្នកធ្វើកំណត់ហេតុ**

វរសេនីយ៍ទោ ឡឹក_សញ្ញា

**គោរពជូន**

**លោកជំទាវអនុប្រធានអចិន្ត្រៃយ៍**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី២៣ខែមករា ឆ្នាំ២០១៧

ប្រធានលេខាធិការដ្ឋាន

ឧត្តមសេនីយ៍ត្រី គង់_ពុទ្ធី

02/02/17

ជូ_ប៊ុនអេង